ផ្សារមូលបត្រកម្ពុជា

CSX

ក្រុមហ៊ុន ផ្សារមូលបត្រកម្ពុជា

លេខៈ ......១៣៣/២០.........

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ថ្ងៃច័ន្ទ ៣រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែតុលា ឆ្នាំ ២០២០

## សេចក្ដីជូនដំណឹង

## ក្រុមហ៊ុន អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី គ្រងជ័យលាភីឈ្នួញជើងសារមូលបត្រឆ្នើមបួនត្រីមាសជាប់គ្នា

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (**ផ.ម.ក.**) មានកិត្តិយសសូមជម្រាបជូនសាធារណជន មេត្តាជ្រាបថា ជ័យលាភីឈ្នួញជើងសារមូលបត្រឆ្នើម សម្រាប់ត្រីមាសទី៣ ឆ្នាំ២០២០ គឺ **ក្រុមហ៊ុន អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី**។ នេះជាត្រីមាសទីបួនហើយ ដែលក្រុមហ៊ុនមូលបត្រមួយនេះបានឈ្នះក្នុងកម្មវិធីនេះ ដោយទទួលបានពិន្ទុខ្ពស់ជាងគេក្នុងចំណោមឈ្នួញជើងសារមូលបត្រទាំង ១០ ដែលជាសមាជិករបស់ **ផ.ម.ក.** ដែលការវាយតម្លៃនេះគឺផ្អែកលើលក្ខណៈវិនិច្ឆ័យចំនួន ៣ គឺ ទំហំជួញដូរមូលត្រសរុបរបស់អតិថិជន ចំនួនគណនីជួញដូរដែលបានបើកថ្មី និងការប្រើប្រាស់ប្រព័ន្ធជួញដូរចល័ត (MTS)របស់អតិថិជន។

នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២០ នេះ ទំហំជួញដូរភាគហ៊ុនសរុបរបស់អតិថិជនក្រុមហ៊ុន អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី មានចំនួន ៣៧,០៥ ប៊ីលានរៀល ពោលគឺស្មើនឹងប្រមាណ៦២% នៃទំហំជួញដូរភាគហ៊ុនសរុប។ ទន្ទឹមនឹងនេះ ៥១%នៃចំនួនគណនីជួញដូរទាំងអស់ដែលបានបើកថ្មីជាចំណែករបស់ក្រុមហ៊ុននេះផងដែរ។ ទំហំជួញដូរសរុបរបស់អតិថិជនក្រុមហ៊ុន អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ីតាមរយៈប្រព័ន្ធ MTS មានចំនួន ៣៦,៤១ ប៊ីលានរៀល ខណៈដែលចំនួនគណនីជួញដូរតាមប្រព័ន្ធ MTS ដែលបានបើកថ្មី មានចំណែក ៧៣% នៃគណនីបើកថ្មីសរុប។

គួររំលឹកផងដែរថា កម្មវិធីឈ្នួញជើងសារមូលបត្រឆ្នើមនេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងស្វែងរកនូវក្រុមហ៊ុនឈ្នួញជើងសារមូលបត្រឆ្នើមប្រចាំត្រីមាសនីមួយៗ ដែលមានភាពលេចមុខគេក្នុងការផ្ដល់សេវាកម្មឈ្នួញជើងសារមូលបត្រសម្រាប់អតិថិជនរបស់ខ្លួន។

Cambodia Securities Exchange

**ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង÷
លោកស្រី **គីម សុផានីតា** ប្រធាននាយកដ្ឋាន
នាយកដ្ឋានប្រតិបត្តិការទីផ្សារ
អ៊ីម៉ែល÷ sophanita.kim@csx.com.kh